ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា

លេខ.....

ថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣

សេចក្តីជូនដំណឹង
ស្តីពី
ការកំណត់ថ្ងៃដេញថ្លៃ និងការទូទាត់ប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានា (LPCO) សម្រាប់ឥណប្រតិទាន ៧ថ្ងៃ

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យដេញថ្លៃ និងទូទាត់ LPCO ដែលមានឥណប្រតិទាន ៧ថ្ងៃ ជារៀងរាល់ថ្ងៃព្រហស្បតិ៍ (T+0) ដើម្បីសម្រួលដល់ការផ្តល់សន្ធនីយភាពឱ្យទាន់ពេលវេលា។ សេចក្តីជូនដំណឹងនេះនឹងអនុវត្តចាប់ពីថ្ងៃចន្ទ ៨រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។

ចំពោះ LPCO ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ ធនាគារជាតិនៃកម្ពុជានឹងរក្សាការដេញថ្លៃ និងការទូទាត់តាមពេលវេលាដដែល គឺដាក់ឱ្យដេញថ្លៃនៅរៀងរាល់ថ្ងៃអង្គារ និងទូទាត់នៅរៀងរាល់ថ្ងៃព្រហស្បតិ៍។

សេចក្តីជូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមអនុវត្ត តាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ២៣០ ៦៧៥ EXT. ១០៤៨
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨

សារអេឡិចត្រូនិក : lpco_info@nbc.gov.kh

បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖

www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA